# មេរៀនទី២៩៖ យ៉ាកុបបញ្ឆោតអេសាវនិងអ៊ីសាក

## លោកុប្បត្តិ ២៥៖ ២៧-៣៤ & ២៧៖ ១-៤០

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/WU2gX8VNLyE

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/WJCjULYBL7g

**គោលបំណង៖** ព្រះចង់ឲ្យយើងមានភាពស្មោះត្រង់

**ខគម្ពីរចងចាំ៖** *សុភាសិត១២៖២២ "បបូរមាត់ដែលពោលពាក្យកុហកជាទីស្អប់ខ្ពើមដល់ព្រះយេហូវ៉ា តែពួកអ្នកដែលប្រព្រឹត្តដោយពិតត្រង់ នោះជាទីគាប់ដល់ព្រះហឫទ័យទ្រង់វិញ"* ។

**ចំរៀង** ( *យូធូបលីង* )៖

១. ចូរប្រយ័ត្នភ្នែកតូច https://youtu.be/leoAGL9usF0

២. បាបខ្ញុំរួចអស់ហើយ https://youtu.be/zosjd2E8cmE

៣. ខ្ញុំថ្វាយបង្គំដ្បិតទ្រង់ជាព្រះ https://youtu.be/1C4guXZFdAw

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត "និយាយពាក្យពិត"

និយាយប្រយោគ ដែលនៅចុងបញ្ចប់នៃប្រយោគនោះត្រូវនិយាយថា *"ខ្ញុំអត់កុហកទេ ឬ ខ្ញុំអត់ភរទេ"*

ឧទាហរណ៍: កូនអាចនិយាយថា "ខ្ញុំបានទៅអង្គរវត្ត ខ្ញុំអត់បានកុហកទេ" ឬក៏ "ខ្ញុំធ្វើកិច្ចការផ្ទះរបស់ខ្ញុំ ហើយៗ ខ្ញុំអត់បានកុហកទេ" ឬ "ខ្ញុំយកចិត្តទុក្ខដាក់ជាមួយបងប្អូនរបស់ខ្ញុំ ខ្ញុំអត់បានភរទេ" ។ កូនក៏ អាចបញ្ឆោតគេផងដែរ ដោយកូនអាចនិយាយអ្វីដែលជារឿងពិត ឬកូនអាចនិយាយអ្វីដែលជារឿងមិន ពិត។ បើវាជារឿងមិនពិតត្រូវខំនិយាយយ៉ាងណា ដើម្បីឲ្យអ្នកផ្សេងជឿលើរឿងដែលកូននិយាយ។ បន្ទាប់មកយើងនឹងសម្រេចចិត្តថាអ្វីដែលកូននិយាយនោះពិតឬអត់។

- តើកូនអាចប្រាប់បានទេថាអ្នកណានិយាយពិតឬនិយាយកុហក? រួចពន្យល់ចម្លើយរបស់កូន។ *(ឧទាហរណ៍៖ បាទ/ចា៎ស ព្រោះពួកគេសើចពេលគេនិយាយមិនពិត, អត់ទេពីព្រោះអ្នកខ្លះពូកែនិយាយធ្វើឲ្យយើងជឿថា វាជារឿងពិត)*
- តើកូនមានអារម្មណ៍យ៉ាងណានៅពេលមាននរណាម្នាក់កុហកកូន? *( ចម្លើយអាចជា៖ខ្ញុំមានអារម្មណ៍ថាពួកគេមិនគោរពខ្ញុំ,ខ្ញុំខឹង,ខ្ញុំមិនទុកចិត្តម្នាក់នោះទៀតទេ)*

ពេលខ្លះវាពិបាកមើលដឹងថានរណានិយាយពិតឬនិយាយកុហកណាស់។ មនុស្សនិយាយកុហកដោយសារហេតុផលជាច្រើន។ តាមធម្មតាពួកគេព្យាយាមលាក់បាំងអ្វីមួយឬពួកគេខ្លាចមានបញ្ហា។ យើងមិនអាចទុកចិត្តគាត់បានទៀតទេ នៅពេលដែលគាត់បានធ្វើឲ្យយើងបាត់បង់ការទុកចិត្តលើគាត់ហើយ នោះ។ ព្រះដឹងថាការទុកចិត្តអ្នកដទៃគឺសំខាន់ខ្លាំងណាស់។ កូនមិនត្រូវសង្ស័យទេយើងអាចទុកចិត្តព្រះ បានពីព្រោះព្រះតែងតែស្មោះត្រង់ ហើយនោះមិនមែនជាការកុហកទេ!

### ៤. ការណែនាំមេរៀន

តើមានអ្នកណាធ្លាប់លួចលុយម៉ាក់ទេ? ឬក៏ ធ្លាប់និយាយកុហកប៉ាម៉ាក់ទេ? ហើយតើមានអ្នកណាធ្លាប់យករបស់មិត្តភក្តិហើយមិនសងគេវិញទេ? មនុស្សគ្រប់គ្នាមានការពិបាកក្នុងការប្រាប់ការពិត ប៉ុន្តែព្រះ

តែងតែស្មោះត្រង់។ បើព្រះជាម្ចាស់មានបន្ទូល នោះវានឹងកើតឡើងមែន! ប្រសិនបើព្រះជាម្ចាស់សន្យាទ្រង់នឹងរក្សាវា! ប្រសិនបើព្រះបង្រៀនអ្វីមួយតាមរយៈព្រះបន្ទូលរបស់ទ្រង់នោះវាគឺជាការពិត ដោយគ្មានការសង្ស័យ! យើងអាចជឿជាក់លើព្រះជាម្ចាស់ ថាទ្រង់តែងតែស្មោះត្រង់ជានិច្ចមិនដូចជាមនុស្សទេ។ នៅក្នុងបទគម្ពីរថ្ងៃនេះយ៉ាកុប និងអេសាវបានបង្ហាញ ថាមនុស្សខុសពីព្រះយ៉ាងដូចម្ដេច។មនុស្សនិយាយកុហកបោកប្រាស់អ្នកដទៃដើម្បីទទួលបានអ្វីដែលពួក គេចង់បាន។ ប៉ុន្តែព្រះមិនដែលធ្វើដូច្នេះទេ។ យើងអាចជឿជាក់បានថា ព្រះតែងតែប្រាប់ការពិតដល់យើង ជានិច្ច។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

បន្ទាប់ពីអ៊ីសាករៀបការជាមួយរេបិកាពួកគេមានកូនប្រុសភ្លោះគឺយ៉ាកុបនិងអេសាវ។ អេសាវជាកូនច្បងគឺជាកូនសំណព្វរបស់អ៊ីសាកហើយយ៉ាកុបជាកូនសំណព្វរបស់រេបិកា។ការស្រឡាញ់កូនមិនស្មើគ្នាវាជារឿងមិនល្អនោះទេ។ ព្រះស្រឡាញ់កូនដូចៗគ្នាទោះបើកូនមិនដូចគ្នាក៏ដោយ!

នៅអ៊ីស្រាអែលការកើតមកជាកូនច្បងមានន័យថាព្រះជាម្ចាស់នឹង ប្រទានមរកតឲ្យកូនច្បង នោះទ្វេដង។ ថ្ងៃមួយ នៅពេលដែលអេសាវមកដល់ផ្ទះគាត់ឃ្លានខ្លាំងណាស់ គាត់បានសុំអាហារពីយ៉ាកុប។ យ៉ាកុបបានប្រើល្បិចបោកប្រាស់អេសាវ ហើយប្រាប់គាត់ថាឲ្យលក់សិទ្ធិជាកូនច្បង ដើម្បីប្តូរយកអាហារមួយពេលនេះទៅ។ អេសាវមិនគិតថាព្រះពរដែលគាត់នឹងទទួលបានពីព្រះក្នុងនាមជាកូនច្បងគឺសំខាន់នោះទេ ដូច្នេះគាត់បានស្បថដោយនិយាយថាគាត់នឹងបោះបង់សិទ្ធិជាកូនច្បងដោយប្តូរជាមួយនឹងអាហារមួយចាននេះ! ព្រះមិនសប្បាយចិត្តទេនៅពេលឃើញយើងបោកប្រាស់ឬកុហកអ្នកដទៃ។ យ៉ាកុបបានធ្វើរឿងដ៏អាក្រក់នៅក្នុងព្រះនេត្ររបស់ព្រះ។

ទោះបីជាអេសាវបាត់បង់សិទ្ធិជាកូនច្បងក៏ដោយ ក៏អ៊ីសាកនៅតែចង់ឲ្យពរដល់អេសាវ មុនពេលគាត់ស្លាប់ ហើយអ៊ីសាកពិតជាចង់ធ្វើបែបនេះខ្លាំងណាស់។ ប៉ុន្តែរេបិកាបានកុហកជាលើកទីពីរ នាងប្រាប់យ៉ាកុបឲ្យស្លៀកពាក់បន្លំខ្លួនជាអេសាវ ហើយទៅសុំពរពីឪពុករបស់គាត់។ ពីព្រោះលោកអ៊ីសាក ពិការភ្នែកហើយមើលអ្វីមិនឃើញ។

ដើម្បីស្វែងយល់ពីរេបិកានៅក្នុង( *លោកុប្បត្តិ ២៥:២៣*) ព្រះបានសន្យាថាកូនប្រុសច្បងរបស់នាងនៅពេលចាស់នឹងបំរើកូនប្អូន។ នាងប្រហែលជាគិតថានាងកំពុងជួយព្រះដោយនិយាយកុហកអ៊ីសាក! ប៉ុន្តែព្រះ មិនត្រូវការជំនួយរបស់យើងទេ ជាពិសេសប្រសិនបើនាងនិយាយកុហកឬបោកបញ្ឆោតដូច្នេះ! មិនថាហេតុផលអ្វីក៏ដោយរេបិកាបានជួយយ៉ាកុបបោកបញ្ឆោត ឪពុកវ័យចំណាស់របស់គាត់ឲ្យផ្ដល់ពរ ដែលបំរុងទុកឲ្យអេសាវ។ ការបោកប្រាស់នេះបានធ្វើឱ្យគ្រួសារមានបញ្ហា។ អេសាវបានប្តេជ្ញាថានឹង សម្លាប់យ៉ាកុបភ្លាមៗនៅពេលដែលឪពុករបស់ពួកគេស្លាប់( *លោកុប្បត្តិ២៧:៤១*)។ យ៉ាកុបត្រូវរត់ចេញពីផ្ទះហើយមិនបានជួបម្ដាយគាត់ទៀតទេ។

## ៦. សំនួរពិភាក្សា

១. តើអ្នកណាជាអ្នកបោកបញ្ឆោតយកព្រះពរពីឪពុក? *(យ៉ាកុប)*

២. តើអ្នកណាបានរួមដៃក្នុងការបោកបញ្ឆោតនោះ? *(ម្ដាយរបស់គាត់ គឺរេបិកា)*

៣. តើយ៉ាកុបនិងម្ដាយរបស់គាត់បញ្ឆោតអ៊ីសាកដោយរបៀបណា? *(គាត់រៀបចំសំឡឲ្យឪពុកគាត់និង បន្លំខ្លួនធ្វើជាអេសាវ )*

៤. តើការកុហកនោះវាជាការល្អឬអាក្រក់? *(មិនល្អទេ ព្រះចង់ឲ្យយើងធ្វើនូវរឿងល្អ ត្រឹមត្រូវស្មោះត្រង់)*

## ៧. ល្បែងកំសាន្ត ល្បែង “ល្អ ឫ អាក្រក់”



- សរសេរ “**ការល្អ**” ឫ “**អាក្រក់**” នៅលើក្រដាសហើយ បិទនៅលើជញ្ជាំង(ធ្វើយ៉ាងណាកុំឲ្យសិស្សមើលឃើញអក្សរ ដែលសរសេរ លើក្រដាសនោះ)

- បន្ទាប់មកចាក់បទចំរៀងហើយឲ្យសិស្សរាំជុំវិញជា រង្វង់នៅពេលដែលចំរៀងឈប់
- សិស្សត្រូវជ្រើសរើសយក ក្រដាសបិទណាមួយនៅ លើជញ្ជាំង ដោយដើរ ទៅឈរនៅទីតាំងដែលបានបិទក្រដាសនោះ។
- ក្រុមដែលរើសយកក្រដាសដែលសរសេរពាក្យ "**ការល្អ**" នោះជាក្រុមដែលឈ្នះ។
- បន្ទាប់ពី លេងហ្គេមចប់ សូមសួរសិស្សថា តើគេមានអារម្មណ៍យ៉ាងម៉េចដែរ នៅពេលដែល គេបានជ្រើសរើសយក"**ការល្អ**"? គ្រូត្រូវជួយរំលឹកសិស្សឲ្យដឹងថា ពួកគេត្រូវមានការប្រុង ប្រយត្ន័ក្នុងការសំរេចចិត្តមុននឹងធ្វើអ្វីមួយ។

## ៨. ខគម្ពីរចងចាំ

**សុភាសិត១២៖២២** *"បបូរមាត់ដែលពោលពាក្យកុតករជាទីស្អប់ខ្ពើមដល់ព្រះយេហូវ៉ា តែពួកអ្នកដែលប្រព្រឹត្តដោយពិត ត្រង់នោះជាទីគាប់ដល់ព្រះហឫទ័យទ្រង់វិញ"*។

**ល្បែងចងចាំខគម្ពីរ៖** <u>កាត់ក្រដាសជា១០ចំរៀកដូចភីហ្សា:</u> សូមជួយកុមារឲ្យចងចាំខគម្ពីរនេះ ដោយសរសេរខគម្ពីរនៅលើចំរៀកក្រដាសដែលយើងបានកាត់រួច។ បន្ទាប់មកឲ្យកុមារទន្ទេញខគម្ពីរទៅតាមចំរៀកក្រដាសនីមួយៗ នៅពេលពួកគេទន្ទេញចប់គ្រូត្រូវដកក្រដាសម្តង ១ចំរៀក រហូតដល់ចំរៀក ទី ១០ ហើយសូមជួយឲ្យកុមារទន្ទេញខគម្ពីរចងចាំទាំងមូល។ ឲ្យកុមារបន្តទន្ទេញខគម្ពីរនោះរហូតដល់ចាំ ខគម្ពីរទាំងអស់។

## ៩. ហាត្ថកម្ម

សំភារៈដែលត្រូវការ៖ ក្រដាស់ ខ្មៅដៃ




- សរសេរពាក្យថា " ល្អ" នៅលើក្រដាសផ្ទាំងធំមួយ និងពាក្យ ថា " អាក្រក់" នៅលើក្រដាសធំមួយទៀតហើយបិទនៅលើ ជញ្ជាំង។
- ចែកក្រដាស ២ សន្លឹកទៅឲ្យសិស្សម្នាក់ៗ ហើយឲ្យសិស្សសរសេរពាក្យ "**ល្អ**" លើក្រដាស ១សន្លឹក ហើយសរសេរពាក្យ "**អាក្រក់**" នៅលើក្រដាស១សន្លឹកទៀត
- សួរសិស្សថា តើអ្វីខ្លះជាអំពើល្អ?។ ហើយឲ្យសិស្សយកក្រដាសដែលគេបានសរសេរពីសកម្មភាពដែលជាអំពើ "**ល្អ**" បិទលើក្រដាសផ្ទាំងធំ ដែលបានសរសេរពាក្យថា " ល្អ" ។
- ធ្វើដូចគ្នាដែរ ដើម្បីឲ្យសិស្សសរសេរនៅលើក្រដាសដែលមានពាក្យថា "អាក្រក់"
- នៅពេលសិស្សបានបិទរួច សូមពន្យល់សិស្សថាដោយសារព្រះតែងតែល្អ យើងព្យាយាម ឲ្យអស់ពីសមត្ថភាពដើម្បីធ្វើខ្លួនឲ្យបានល្អដែរ។
- ឲ្យសិស្សឡើងមកបិទក្រដាសដែលពួកគេបានសរសេរទៅតាមទីកន្លែងដែលត្រឹមត្រូវម្តងម្នាក់ៗ។

(***ហាត្ថកម្ម:ជាជំរើស***) "អ្នកណាដែលទទួលបានព្រះពរពីព្រះ?" (សូមមើលទំព័រខាងក្រោម)

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ: (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
នៅពេលដែលយើងជ្រើសរើសភាពស្មោះត្រង់ហើយទុកចិត្តលើព្រះឲ្យអស់ពីចិត្ត នោះព្រះនឹងសប្បាយព្រះទ័យហើយទ្រង់នឹងការពារយើង។ ផ្លូវនេះវាមិនចេះតែស្រួលនោះទេ តែវាអាចនាំយើងឲ្យមាន ទំនាក់ទំនងល្អជាមួយនឹងព្រះគ្រីស្ទ។ តើអ្នកធ្លាប់មានភាពមិនស្មោះត្រង់ជាមួយព្រះដែរឬទេ?ជាមួយខ្លួនឯងដែរឬទេ? និងជាមួយអ្នកដ៏ទៃ ដែរឬទេ? យើងត្រូវការភាពក្លាហានដើម្បីចាកចេញពីការបោក បញ្ឆោតហើយប្តេជ្ញាចិត្តចំពោះការពិត។ សូមចំណាយពេលបន្តិចដើម្បីសុំឲ្យព្រះដកភាពមិនស្មោះត្រង់ របស់យើងចេញ។ សារភាពពីភាពទន់ខ្សោយរបស់អ្នកទៅកាន់ព្រះជាម្ចាស់ហើយទូលសូមកំលាំងនិងភាព

ស្មោះត្រង់របស់ទ្រង់សម្រាប់យើងវិញ។




សូមសរសេរខគម្ពីរចងចាំ: ______________________________

______________________________________________________

______________________________________________________

______________________________________________________